ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០២៩/១៥.គជប

# សេចក្តីសម្រេច
# ស្តីអំពី
# ការបែងចែកភារកិច្ច ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញអនុក្រឹត្យលេខ២៧៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែ តុលា ឆ្នាំ២០១៤ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញប្រកាសគណៈកម្មាធិការជាតិ លេខ ០០១/១៥ ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពី តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ របស់ការិយាល័យចំណុះលេខាធិការដ្ឋានរដ្ឋបាលសរុប នៃអគ្គលេខាធិការដ្ឋាន របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ
- យោងភាពចាំបាច់នៃអគ្គលេខាធិការដ្ឋាន

## សម្រេច

**ប្រការ១**. ត្រូវបានបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដូចតទៅ៖

១. ឯកឧត្តមឧត្តមសេនីយ៍ឯក **ចៅង សំអាត** អគ្គលេខាធិការ ទទួលបន្ទុកជួយអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ សម្របសម្រួល ចាត់ចែង ដឹកនាំ គ្រប់គ្រង ការងាររួម សំដៅភាពសុខដុមរមនា ក្នុងអគ្គលេខាធិការដ្ឋាន និងធ្វើឲ្យសម្រេចទិសដៅនៃផែនការគណៈកម្មាធិការជាតិ ។

២. ឯកឧត្តម **យ៉ែម ច័ន្ទណារ៉ុ** អគ្គលេខាធិការរង គ.ជ.ប.ជ ទទួលបន្ទុក គ្រប់គ្រងការិយាល័យទាំងប្រាំ នៃលេខាធិការដ្ឋាន រដ្ឋបាលសរុប ។

៣. ឯកឧត្តម **ចាន់ សុវណ្ណា** អគ្គលេខាធិការរង គ.ជ.ប.ជ ទទួលបន្ទុក
ដឹកនាំក្រុមមន្ត្រីជំនួយកិច្ចការបង្ការទប់ស្កាត់

៤. ឯកឧត្តម ឧត្តមសេនីយ៍ទោ **ខៀវ ចាន់រ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ ទទួលបន្ទុក
ដឹកនាំក្រុមមន្ត្រីជំនួយកិច្ចការទេសន្តរប្រវេសន៍

៥. ឯកឧត្តម ឧត្តមសេនីយ៍ទោ **ឃឹម ខារៈ** អគ្គលេខាធិការរង គ.ជ.ប.ជ ទទួលបន្ទុក
ដឹកនាំក្រុមមន្ត្រីជំនួយកិច្ចការយុត្តិធម៌

៦. ឯកឧត្តម ឧត្តមសេនីយ៍ទោ **ស៊ុន រ៉ូ** អគ្គលេខាធិការរង គ.ជ.ប.ជ ទទួលបន្ទុក
ដឹកនាំក្រុមមន្ត្រីជំនួយកិច្ចការអនុវត្តច្បាប់

៧. លោកជំទាវ **ម៉ុណ្ណា សំខាន់** អគ្គលេខាធិការរង គ.ជ.ប.ជ ទទួលបន្ទុក
ដឹកនាំក្រុមមន្ត្រីជំនួយកិច្ចការការពារជនរងគ្រោះ

៨. លោកជំទាវ **រ៉ែន សិរីវឌ្ឍនា** អគ្គលេខាធិការរង គ.ជ.ប.ជ
ទទួលបន្ទុកដឹកនាំក្រុមមន្ត្រីជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ និង ព័ត៌មានវិទ្យា ។

**ប្រការ២**. អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវជួយសហការ បំពេញការងារពាក់ព័ន្ធ
ឲ្យសម្រេចលទ្ធផល និងធ្វើកិច្ចការ ឬបេសកកម្មដទៃទៀត
តាមការប្រគល់ជូនពីអនុប្រធានអចិន្ត្រៃយ៍ ឬពីប្រធានគណៈកម្មាធិការជាតិ ។

**ប្រការ៣**. បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤**. អនុប្រធានអចិន្ត្រៃយ៍ទទួលបន្ទុកអគ្គលេខាធិការដ្ឋាន លេខាធិការដ្ឋាន
ក្រុមមន្ត្រីជំនួយការអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងសាមីខ្លួនដូចប្រការ១ត្រូវទទួលអនុវត្ត
តាមស្មារតីនៃសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥

**ប្រធានគណៈកម្មាធិការជាតិ**

**សម្តេចក្រឡាហោម ស ខេង**

កន្លែងទទួល៖

- ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ
- ប្រធានក្រុមការងារអន្តរក្រសួងស្ថាប័នទាំង០៦
- សមាជិកគ.ជ.ប.ជ
- សាមីខ្លួន ដូចប្រការ១
- ឯកសារ កាលប្បវត្តិ